# បត្តិទានគាថា

ពុទ្ធសាសនិកជនដែលបានធ្វើកុសលអែណាមួយហើយ បើមានប្រាថ្នានឹងអោយចំរើនផលានិសង្សដល់ខ្លួនដោយច្រើនឡើងទៀតនោះ គប្បីអុទ្ទិស ផ្សាយផលកុសលនោះដល់សត្វទាំងឡាយ ដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុម្យ៉ាង ដែលហៅថា បត្តិទាន គឺកិរិយាអោយចំណែកដល់អ្នកដទៃ ដោយបត្តិទានកថានេះដូច្នេះថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចាមនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ

ប្រែថា : យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលអែណាមួយដែលខ្ញុំ គប្បីធ្វើ កាយេន វាចាមនសា ដោយទ្វារទាំងបី គឺកាយវាចាចិត្ត តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំអោយទៅកើតក្នុងស្ថានត្រៃត្រឹង្សសួគ៌ បាន យេ សត្តា សញ្ញិនោ សត្វទាំងឡាយអែណាគឺ មនុស្ស រឺទេវតា រឺព្រហ្មដែលជាសត្វមានសញ្ញាក្តី អត្ថិ យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយអែណា ជាអសញ្ញិសត្វ គឺសត្វអិតសញ្ញាក្តី កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះចូរបានចំណែកផលនៃបុណ្យ ហើយ ចូរសោយផលនៃបុណ្យ

ដែលខ្ញុំបានធ្វើហើយ បានអុទ្ទិសផ្សាយអោយទៅនេះចុះ យេ ច តត្ថ នជាននិ្ត ម្យ៉ាងទៀតបណ្តាសត្វទាំងនោះ បើសត្វទាំងឡាយអែណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ ទេវា គន្ទា និវេទយុំ សូមទេវតាទាំងឡាយ អញ្ជើញទៅអោយដំណឹងដល់សត្វទាំងឡាយនោះ អោយបានដឹងថាជនអែណោះ គេបានធ្វើបុណ្យ ហើយ គេអុទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនិងបុណ្យគេនោះចុះ សព្វេ លោកម្ហិ យេ សត្តា ជីវន្តា ហារហេតុកា សត្វទាំងឡាយអែណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះចូរអោយបាននូវភោជនជាទីគាប់ចិត្ត ដែលសំរេចដោយបុញ្ញរិទ្ធ តាមចិត្ត ដែលខ្ញុំអុទ្ទិស ផ្សាយទៅអោយនេះចុះ។

## បត្តិទានគាថា

យា ទេវតា សន្តិ វិហារវាសនី ថូបេឃរេ ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី អុបាសកា គាមា ច ទេសា និគមា ច អិស្សរា សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ។ ថាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ សមគ្គោវ អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ

យា ទេវតា សន្តិ វិហារវាសនី ថូបេយរេ ពោធិយរេ តហឹ តហឹ ទេវតាទាំងឡាយ អែណាមានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃអែង៏ខឿនព្រះសថូប អែង៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះៗ តា ធម្មទានេន ភវន្តុ បូជិតា ទេវតាទាំងឡាយនោះជាបុគ្គល គឺយើងទាំងឡាយបូជាហើយដោយធម្មទាន សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសេរីសួស្តីក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី សារាមិកា ទានបតី អុបាសកា អុបាសក និងអុបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី គាមា ច ទេសា និគមា ច អិស្សរា ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាអិស្សរជនធំក្តី សប្បាណភូតា សុខិតាភវន្តុ តេ សត្វទាំងឡាយនោះៗ ចូរអោយបានដល់នូវសេចក្តីសុខ ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា មួយវិញទៀត សត្វទាំងឡាយអែណា ដែលជា ជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ សត្វទាំងឡាយទាំងអស់នោះកាលបើ បានអាស្រ័យនូវធម៌ដ៏ប្រសើរជានិយ្យនិកធម៌ហើយ ចូរធ្វើនូវធម៌ ជាគ្រឿងអស់ទៅនៃ សេចក្តីទុក្ខចុះ ថាតុ ចិរំ សតំ ធម្មោ សូមអោយធម៌របស់សប្បុរសទាំងឡាយ ស្ថិតនៅអស់កាលយូរអង្វែងទៅ ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ) សង្ឃោ ហោតុ សមគ្គោវ សូមព្រះសង្ឃព្រមព្រៀងគ្នា

អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចំរើនផង ដើម្បីសេចក្តីសំរេចផលប្រយោជន៍ផង អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង វុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ សូមយើងទាំងឡាយបានដល់នូវសេចក្តីចំរើនក្នុងធម៌ដែលព្រះអរិយទាំងឡាយលោកសំដែងហើយ។

បត្តិទានគាថានេះ សំរាប់សូត្រចំពោះតែក្នុងទីវត្តអារាម ក្នុងកាលដែលចប់ធម៌ទេសនា រឺក្នុងវេលាដែលសូត្រធម៌ណាចប់ហើយ។

## សុខាភិយាចនគាថាសង្ខេប

បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ សម្មា ធារំ បវេច្ឆន្តោ កាលេទេវោ បវស្សតុ វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ អេវំ ធម្មេន រាជា នោ បជំ រក្ខន្តុ សព្វទា

បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ សត្វទាំងឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា សម្មាធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ វុឌ្ឍីភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ សូមអោយភ្លៀងបង្អុរនូវធារទឹកដ៏ប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្តាលអោយផែនដីសំរិទ្ធ គឺថាចូរអោយមានជីវជាតិល្អឡើង ដើម្បីអោយកើត សេចក្តីចំរើន

ដល់សត្វទាំងឡាយ មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ មាតាក្តី បីតាក្តី បីបាច់រក្សាជានិច្ចនូវកូនតូច ជាកូនបង្កើត យ៉ាងណាមិញ អេវំ ធម្មេន រាជា នោ បជំ រក្ខន្តុ សព្វទា សូមព្រះបរមក្សត្រទាំងឡាយ រក្សានូវប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតា បីបាច់រក្សាកូនដូច្នោះ អោយបានសព្វកាលទៅហោង។